# សិក្ខាសាលាស្តីពី
# ការពិនិត្យមើលការអនុវត្តន៍ផែនការសកម្មភាពជាតិ និង
# កិច្ចសហការពីអង្កេតតាមដាន និងការចែករំលែកទិន្នន័យ
# AMR/AMU នៅកម្ពុជា

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាតិ គ្រប់គ្រងលើការប្រើប្រាស់ឱសថប្រឆាំងមេរោគ

National Legislation/Regulation for Controlling Antimicrobial Agents

បង្ហាញដោយៈ លោក គា ផា អនុប្រធាននាយកដ្ឋានផ្សព្វផ្សាយបច្ចេកទេស និង
នីតិកម្ម នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ





# ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តគ្រប់គ្រងលើការប្រើប្រាស់ឱសថប្រឆាំងមេរោគក្នុងវិស័យសុខភាពសត្វ និងផលិតកម្មសត្វ




ច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ

- ❑ ចូលជាធរមាននៅថ្ងៃទី ២៨ ខែ មករា ឆ្នាំ២០១៦
- ❑ មាន២២ជំពូក
- ❑ ព្រះរាជក្រឹត្យចំនួន១
- ❑ អនុក្រឹត្យ៥
- ❑ ប្រកាស៣៣

# អនុក្រឹត្យលេខៈ ២៦អនក្រ.បក ចុះថ្ងៃទី ០២ ខែមីនា ឆ្នាំ២០០១ ស្តីពីការបង្កើត និងគ្រប់គ្រងភ្នាក់ងារសុខភាពសត្វភូមិ

- អនុក្រឹត្យនេះ ជាសេនាធិការរបស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ក្នុងគោលបំណងបង្កើនមុខរបរសម្រាប់ប្រជាពលរដ្ឋ និងបង្កើនផលិតភាព និងគុណភាពសត្វ ឱ្យស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលស្តីពីភាវូបនីយកម្មក្នុងវិស័យសុខភាពសត្វ និងផលិតកម្មសត្វ សំដៅរួមចំណែកកាត់បន្ថយភាពក្រីក្រនៅតាមជនបទ និងជំងឺឆ្លងសត្វក្នុងមូលដ្ឋាន និងជំងឺឆ្លងដែន ជាពិសេសជំងឺអុតក្តាម និងជំងឺឆ្លងសត្វផ្សេងៗទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- បានចូលជាធរមាននៅថ្ងៃទី ០២ ខែមីនា ឆ្នាំ២០០១
- មាន ០៥មាត្រា
- ប្រកាស់ ០៣៖
  - ប្រកាស់លេខៈ ២៨៨ប្រក.កសក ស្តីពីនីតិវិធីនៃការជ្រើសរើសនិងការបណ្តុះបណ្តាលភ្នាក់ងារសុខភាពសត្វភូមិ លជាធរមាននៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០១
  - ប្រកាស់លេខៈ ២៨៩ប្រក.កសក ស្តីពីការជ្រើសរើសគ្រូបណ្តុះបណ្តាលភ្នាក់ងារសុខភាពសត្វភូមិលជាធរមាននៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០១

# អនុក្រឹត្យលេខៈ ២៦អនក្រ.បក ចុះថ្ងៃទី ០២ ខែមីនា ឆ្នាំ២០០១ ស្ដីពីការបង្កើត និងគ្រប់គ្រងភ្នាក់ងារសុខភាពសត្វភូមិ (ត)

- ប្រកាសលេខៈ ៣៦៨ប្រក.កសក ស្ដីពីការបង្កើតគណៈកម្មការចុះបញ្ជិកា និងការផ្ដល់លិខិតអនុញ្ញាតសេវាកម្មផលិតកម្ម និងបសុព្យាបាល ចូលជាធរមាននៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០១

- ភ្នាក់ងារសុខភាពសត្វភូមិនេះ មិនមែនជាភ្នាក់ងាររដ្ឋទេ គឺជាភ្នាក់ងារដែលជ្រើសរើសក្នុងចំណោមប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន ឬសិស្ស និស្សិត ដែលបានទទួលការបណ្ដុះបណ្ដាល មកទទួលការបណ្ដុះបណ្ដាល និងបំប៉ន់បច្ចេកទេសពីក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ។

# អនុក្រឹត្យលេខៈ ១៦អនក្រ. បក ថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០០៣
# ស្តីពីការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ

- អនុក្រឹត្យនេះ មានគោលបំណងកំណត់ការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ដើម្បីទប់ស្កាត់ការរាលដាលនៃជំងឺឆ្លងសត្វ និងការការពារសុខភាពសាធារណៈ ដោយអនុវត្តវិធានបសុពេទ្យលើរាល់ការនាំចូល នាំចេញ ឆ្លងកាត់ និងដឹកជញ្ជូនទំនិញដែលជាកម្មវត្ថុនៃការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វពីតំបន់មួយ ទៅតំបន់មួយទៀត ក្នុងព្រះរាជាណាចក្រកម្ពុជា តាមគ្រប់មធ្យោបាយចម្លងជំងឺសត្វ ឬផលិតផលមានដើមកំណើតពីសត្វទៅសត្វ ឬពីសត្វទៅមនុស្ស ឬពីមនុស្សទៅសត្វ។
- អនុក្រឹត្យលេខៈ១៦អនក្រ. បក បានចូលជាធរមាននៅថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០០៣
- មាន០៩ជំពូក
- មាន ៣៤មាត្រា និង
- ប្រកាស ០៦៖
    - ប្រកាសលេខៈ ២១២ប្រក.កសកស្តីពិការបង្កើតកងកសណ្ឋាន និងសញ្ញាសម្គាល់របស់មន្ត្រីត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ បានចូលជាធរមាននៅថ្ងៃទី២១ ខែកក្កដា ឆ្នា ២០០៤

# អនុក្រឹត្យស្តីពីការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ (ត)

- ប្រកាសលេខៈ ០១៤ប្រក.កសក ស្តីពីបញ្ជីរាយឈ្មោះជំងឺឆ្លងសត្វ ចូលជាធរមាននៅថ្ងៃទី ២៤ ខែមករា ឆ្នាំ២០០៦(មាន ៧ ប្រការ និង២ឧបសម្ព័ន្ធ)
  - ឧបសម្ព័ន្ធទី១ បញ្ជីរាយឈ្មោះជំងឺឆ្លងរាតត្បាតសត្វគ្រប់ប្រភេទក្នុងក្រុម"ក"
  - ឧបសម្ព័ន្ធទី១ បញ្ជីរាយឈ្មោះជំងឺឆ្លងរាតត្បាតសត្វគ្រប់ប្រភេទក្នុងក្រុម"ខ"
- ប្រកាសលេខៈ ២២៧ ប្រក.កសក ស្តីពីបែបបទនៃការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ក្នុងស្រុក ចូលជាធរមាននៅថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ២០០៨
- ប្រកាសរួមលេខៈ ៤៤៥ប្រក.កសក និងលេខៈ ៨៨៤សហវ.ប្រក ស្តីពីសោហ៊ុយសេវាកម្មត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ចូលជាធរមាននៅថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០០៨
- ប្រកាសរួមលេខៈ ០៥០ប្រក.កសក និងលេខៈ ១២៨សហវ.ប្រក ស្តីពីប្រាក់រង្វាន់លើកទឹកចិត្តដល់មន្ត្រីដែលបានចូលរួមបង្ក្រាបបទល្មើសអនាម័យសត្វ សាច់ និងផលិតផលមានដើមកំណើតពីសត្វ ចូលជាធរមាននៅថ្ងៃទី ២៧ ខែមករា ឆ្នាំ២០០៩
- ប្រកាសលេខៈ ១៧៨ ប្រក.កសក ស្តីពីនីតិវិធីនៃការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ចូលជាធរមាននៅថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ២០០៨។

# អនុក្រឹត្យស្ដីពីការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ (ត)

- ប្រកាសរួមលេខៈ ១៤៥ ប្រក.កសក.កយ ស្ដីពីការដាក់ឱ្យប្រើគំរូសំណុំដោះស្រាយបទល្មើសអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ដល់មន្ត្រីនគបាលយុត្តិធម៌របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចូលជាធរមាននៅថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០០៦
- ប្រកាសលេខៈ ០១៦ ប្រក.កសក ស្ដីពីការកែសម្រួលខ្លឹមសារប្រការ៤ នៃប្រកាសលេខៈ១៧៨ប្រក.កសក ចុះថ្ងៃទី ១៨ ខែឧសភា ឆ្នាំ២០០៩ ស្ដីពីនីតិវិធីនៃការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ចូលជាធរមាននៅថ្ងៃទី ១៨ ខែមករា ឆ្នាំ២០១០

# អនុក្រឹត្យ១០៨ អនក្រ. បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលមានដើកំណើតពីសត្វ

- អនុក្រឹត្យនេះ កំណត់ការគ្រប់គ្រងសត្តឃាតដ្ឋាន សកម្មភាពអាជីវកម្មពិឃាតសត្វ ការត្រួតពិនិត្យអនាម័យសត្វសាច់ និងផលិតផលសត្វ នៅតាមសត្តឃាតដ្ឋាន និងកន្លែងតាំងលក់ ក្នុងគោលបំណង ដើម្បីទប់ស្កាត់ការរីករាលដាលជំងឺសត្វ ការពារសុខភាបសត្វ ធានាគុណភាពផលិតផល និងការពារសុខភាពសាធារណៈ ក្នុងព្រះរាជាណាចក្រកម្ពុជា។
- អនុក្រឹត្យ១០៨ អនក្រ.បក បានចូលជាធរមាន នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៧
- អនុក្រឹត្យនេះ មាន០៨ជំពូក
- មាន ២៣មាត្រា
- មាន០៧ ប្រកាស
  - ប្រកាសលេខៈ ២២៦ ប្រក.កសក ស្តីពីគំរូលិខិតអនុញ្ញាត្ត ទម្រង់ បែបបទបង្កើតសត្តខាតដ្ឋាន និងការធ្វើអាជីវកម្មពិឃាតសត្វ ចូលជាធរមាននៅថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ២០០៨
  - ប្រកាសលេខៈ ៤៦៣ ប្រក.កសក ស្តីពីបែបបទ និងបទបញ្ជាបសុពេទ្យក្នុងពេលដឹកជញ្ជូនសាច់ និងផលិតផលសត្វ ចេញពីសត្តឃាតដ្ឋាន ចូលជាធរមាន នៅថ្ងៃទី ២២ខែតុលា ឆ្នាំ២០០៨
  - ប្រកាសលេខៈ ១៣១ ប្រក.កសក ស្តីពីនីតិវិធីនៃការត្រួតពិនិត្យសត្តឃាតដ្ឋាន អនាម័យសត្វ សាច់ នងិផលិតផលសត្វ ចូលជាធរមាននៅថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ២០០៨

## អនុក្រឹត្យ១០៨ អនក្រ. បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៧
## ស្តីពីការគ្រប់គ្រង
## សត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលមានដើកំណើតពីសត្វ(ត)

- ប្រកាសលេខៈ ៦២២ ប្រក.កសក ស្តីពពីប្រភេទត្រា ឬស្លាកបសុពេទ្យសម្រាប់សម្គាល់ការត្រួតពិនិត្យៈនាម័យសាច់ និងផលិតផលសត្វ ចូលជាធរមាននៅថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០១០
- ប្រកាសលេខៈ ១៣៤ ប្រក.សហវ/កសក ស្តីពីការប្រមូលកម្រៃសេវាកម្មត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វ នៅសត្តឃាតដ្ឋាន ចូលជាធរមាននៅថ្ងៃទី ១៨ ខែឧសភា ឆ្នាំ២០០៩
- ប្រកាសលេខៈ ២២៤ ប្រក.កសក ស្តីពីបទបញ្ជាផ្ទៃក្នុងរបស់សត្តឃាតដ្ឋានចូលជាធរមាននៅថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ២០០៨
- ប្រកាសលេខៈ ២២៥ប្រក.កសក ស្តីពីទីតាំង និងបទដ្ឋានបច្ចេកទេសសម្រាប់សាងសង់សត្តឃាតដ្ឋាន និងការធ្វើអាជីវកម្មពិឃាតសត្វ ចូលជាធរមាននៅថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ២០០៨។

# លិខិតបទដ្ឋានគតិយុត្តដែលបានរៀបចំរហូតឆ្នាំ២០២៣

| | | |
|---|---|---|
| ១ | ប្រកាសស្តីពីការដាក់ឱ្យប្រើប្រាស់ឧបសម្ព័ន្ធបន្ថែមទៅក្នុងប្រកាសលេខ០៥១ ប្រក.កសក ស្តីពីនីតិវិធី និងការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីចំណីសត្វ វត្ថុធាតុដើម និងសារធាតុបន្ថែម និងប្រកាសលេខ២២៣ ប្រក.កសក ស្តីពីនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាត និងកំណត់ការគ្រប់គ្រងចំណីសត្វ វត្ថុធាតុដើម ឬសារធាតុបន្ថែមដែលធ្វើពាណិជ្ជកម្ម ការផលិត និងធ្វើការលាយផ្សំ។ | សម្រេចស្លាពរ ក្រោមប្រកាសលេខ ២៥៣ ប្រក.កសក |
| ២ | ប្រកាសស្តីពីការដាក់ឱ្យប្រើប្រាស់ឧបសម្ព័ន្ធបន្ថែមទៅក្នុងប្រកាសលេខ២០៨ ប្រក.កសកស្តីពីនីតិវិធី និងការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីបសុឱសថ និងប្រកាសលេខ៤១៤ ប្រក.កសក ស្តីពីនីតិវិធីនៃការចេញលិខិតអនុញ្ញាត និងបទដ្ឋានបច្ចេកទេសនៃការនាំចូល ការនាំចេញ ការនាំឆ្លងកាត់ ការផលិត ការលាយផ្សំ ការវេចខ្ចប់ជាថ្មី ការធ្វើសន្និធិ ការផ្គត់ផ្គង់ចែកចាយ ការលក់ដុំលក់រាយ និងការដឹកជញ្ជូនបសុឱសថ។ | សម្រេចស្លាពរ ក្រោមប្រកាសលេខ ២៥៤ ប្រក.កសក |
| ៣ | ប្រកាសស្តីពីនីតិវិធី និងសិទ្ធិពិន័យអន្តរការណ៍លើបទល្មើស (មាត្រា១០៧)។ | សម្រេចស្លាពរ ក្រោមប្រកាសលេខ ៣៤៣ ប្រក.កសក |
| ៤ | ប្រកាសស្តីពីនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាតនិងកំណត់ការគ្រប់គ្រងចំណីសត្វ វត្ថុធាតុដើម ឬសារធាតុបន្ថែមដែលត្រូវធ្វើពាណិជ្ជកម្ម ការផលិត និងធ្វើលាយផ្សំ (មាត្រា៤៩)។ | សម្រេចស្លាពរ ក្រោមប្រកាសលេខ ២២៣ ប្រក.កសក |
| ៥ | ប្រកាសស្តីពីការតម្រូវបមាណីយចំណីសត្វ វត្ថុធាតុដើម និងសារធាតុបន្ថែម (មាត្រា៤៤)។ | សម្រេចស្លាពរ ក្រោមប្រកាសលេខ ០៥១ ប្រក.កសក |

| | | |
|---|---|---|
| ៦ | ប្រកាសស្តីពីនីតិវិធីនៃការគ្រប់គ្រងបសុឱសថ និងវត្ថុធាតុជីវ បសុព្យាបាលដែលត្រូវធ្វើពាណិជ្ជកម្មនិងធ្វើការលាយផ្សំ (មាត្រា៣៩) | សម្រេចស្ថាពរ ក្រោមប្រកាសលេខ ៣៨៤ ប្រក.កសក ស្តីពីនីតិវិធីនៃការគ្រប់គ្រងបសុឱសថ និងវត្ថុធាតុជីវៈ បសុព្យាបាល ដែលធ្វើពាណិជ្ជកម្ម និងធ្វើការលាយផ្សំ |
| ៨ | ប្រកាសស្តីពីការតម្រូវបមាណីយបសុឱសថ (មាត្រា៣៤)។ | សម្រេចស្ថាពរ ក្រោមប្រកាសលេខ ២០៨ ប្រក.កសក ស្តីពីនីតិវិធី និងការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីបសុឱសថ |
| ៩ | ប្រកាសស្តីពីចំណាត់ថ្នាក់ខ្នាត និងបទដ្ឋានបច្ចេកទេសសម្រាប់ការចិញ្ចឹមសត្វ និងការបង្កាត់ពូជសត្វ ព្រមទាំងនីតិវិធីសម្រាប់ការផ្តល់លិខិតអនុញ្ញាតការចិញ្ចឹមសត្វ (មាត្រា២៤)។ | សម្រេចស្ថាពរ ក្រោមប្រកាសលេខ ៥៤៩ ប្រក.កសក ស្តីពីចំណាត់ថ្នាក់បទដ្ឋានបច្ចេកទេស និងនីតិវិធីសម្រាប់ការផ្តល់លិខិតអនុញ្ញាតការចិញ្ចឹមសត្វ និងការបង្កាត់ពូជសត្វ |

# បទដ្ឋានគតិយុត្តដែលបានអនុម័ត

ជំពូកទី៦ បសុឱសថ

- ប្រកាសលេខ២០៨ ប្រក.កសក ចុះថ្ងៃពុធ ១១កើត ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨ ស្តីពីនីតិវិធី និងការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីបសុឱសថ


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
លេខ ២០៨ ប្រក.កសក

ប្រកាស
ស្តីពី
នីតិវិធី និងការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីបសុឱសថ

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៦/០០៣ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៨ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារ ភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្ម

- ១ -

## បញ្ជីឈ្មោះឱសថ សារធាតុសកម្ម ឬសមាសធាតុ ហាមឃាត់(Prohibited medicine/substance)

-Chloramphenicol and its salts and derivatives

-Clenbuterol and its salts and derivatives

-Diethylstilbestrol or other stilbene compounds (DES)

-Glycopeptides, Vancomycin

-nitrofuran compound,



- **បញ្ជីឈ្មោះឱសថ សារធាតុសកម្ម ឬសមាសធាតុ ដាក់កំហិត**(Restricted medicine/substance)

-Sulfonamide drugs ហាមប្រើក្នុងដំណាក់កាលយកទឹកដោះ

-Phenylbutazone ហាមប្រើលើមេគោបំរុងយកទឹកដោះដែលមានអាយុលើសពី២០ខែ

-Cephalosporins (not including cephapirin) ប្រើសម្រាប់តែការព្យាបាលប៉ុណ្ណោះលើគោក្របី ជ្រូក និងមាន់ទា

-NONMEDICAL GRADE DIMETHYLSULFOXIDE (DMSO) ហាមប្រើក្នុងកសិដ្ឋានចិញ្ចឹមគោទឹកដោះ

-DIPYRONE ហាមប្រើក្នុងកសិដ្ឋានចិញ្ចឹមគោទឹកដោះ

-COLLOIDAL SILVER ហាមប្រើ និងរក្សាទុកក្នុងកសិដ្ឋានចិញ្ចឹមគោទឹកដោះ

-ការប្រើបសុឱសថ Fenthion, Famphur and Xylene, Phosmet, Levamisole and all ivermectins and avermectins ក្នុងកសិដ្ឋានចិញ្ចឹមគោទឹកដោះត្រូវមានការអនុញ្ញាតជាមុន

-Substances in schedule I (lack of accepted safety for use under medical supervision, and a high potential for abuse)

# បទដ្ឋានគតិយុត្តដែលបានអនុម័ត

## ជំពូកទី៧ ចំណីសត្វ

- ប្រកាសលេខ០៥១ ប្រក.កសក ចុះថ្ងៃអង្គារ ១៥រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៨ ស្តីពីនីតិវិធី និងការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីចំណីសត្វ វត្ថុធាតុដើម និងសារធាតុបន្ថែម
- បមាណីយចំណីជ្រូក ចំណីមាន់ ចំណីទា និងចំណីគោ-ក្របី
- អគ្គនាយកដ្ឋានសុខភាព និងផលិតកម្មសត្វ ត្រូវសិក្សា និងកំណត់បមាណីយចំណីសត្វផ្សេង ទៀតតាមការចាំបាច់។



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
លេខ ០៥១ ប្រក.កសក

ប្រកាស
ស្តីពី
នីតិវិធីនៃការចុះបញ្ជី និងការតម្រូវបមាណីយចំណីសត្វ
វត្ថុធាតុដើម និងសារធាតុបន្ថែម

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៦/០០៣ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ដែលប្រកាសដាក់ឱ្យប្រើប្រាស់ច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ
- បានឃើញអនុក្រឹត្យលេខ១៧/អនក្រ/បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានផលិតកម្ម និងបសុពេទ្យ ទៅជាអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- យោងតាមសំណើរបស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ

១

- សារធាតុបន្ថែមហាមឃាត់ប្រើប្រាស់ក្នុងចំណីសត្វ**Prohibited Feed Additives**

**១. អង់ទីប៊ីយ៉ូទិកហាមឃាត់ (Prohibited Antibiotics)**

-Chloramphenicol

-Clenbuterol

-Fluoroquinolones

-Glycopeptides, Vancomycin

-Nitroimidazoles, Dimetridazole, Ipronidazole, Metronidazole និងថ្នាក់របស់វាផ្សេងទៀត

-Nitrofurans, Furazolidine, Nitrofurazone និងថ្នាក់របស់វាផ្សេងទៀត

-Sulfonamide

-Vancomycin

-អង់ទីប៊ីយូទិកហាមឃាត់ដទៃទៀត ដែលមានចែងក្នុង Codex Alimentarius

**២. សារធាតុជំរុញការលូតលាស់របស់សត្វដែលហាមឃាត់ (Prohibited Hormones)**

**៣. ផលិតផលសារពាង្គកាយរស់កែច្នៃសេនេទិកហាមឃាត់ (Prohibited Genetically Modified Organisms)**

# ចំនួនក្រុមហ៊ុនបសុឱសថ និងចំណីសត្វដែលបានចុះបញ្ជី

- 1) EAST HOPE ANIMAL NUTRITION (5មុខ សារធាតុបន្ថែម)
- 2) BM FEED CAMBODIA (21មុខ ចំណីសត្វ)
- 3) INVIVO NSA (12មុខ ចំណីសត្វ)
- 4) CP CAMBODIA (174មុខ បសុឱសថ)
- 5) MEDIVET (25មុខ បសុឱសថ)
- 6) REACH SEY S K (16មុខ ចំណីសត្វ)
- 7) GREEN FEED (73មុខ ចំណីសត្វ)

# គំរូវិញ្ញាបនបត្រសម្រាប់ការចុះបញ្ជីបសុឱសថ



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ
លេខ: សផស/នផបន ថ្ងៃ ខែបឋមសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី ខែកក្កដា ឆ្នាំ២០១៨

**វិញ្ញាបនបត្រចុះបញ្ជីបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម សមាសធាតុ**
**REGISTRATION CERTIFICATION**

យោងតាមចំណារសម្រេចអនុញ្ញាតរបស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨

| | |
|---|---|
| **លេខបញ្ជិកា** (Registration Number) | : **PR01 0212/0718 MV - GDAHP** |
| **ឈ្មោះពាណិជ្ជកម្ម** (Trade Name) | : **ENCEFAL-VAC** |
| **ឈ្មោះទូទៅ** (Common Name) | : **ENCEFAL-VAC** |
| **ប្រភេទនៃទម្រង់ផ្សំ** (Type of Formulation) | : ម្សៅ និងរាវ<br>: Powder and Solution |
| **បរិមាណធាតុសកម្ម** (Content of Active Ingredient) | : Not less than $10_3$ EID$_{50}$ |
| **ប្រភេទបសុឱសថ** (Type of vet drug) | : ថ្នាំបង្ការជំងឺសត្វ |
| **ផ្តល់ជូនចំពោះ** (Issued to) | : ក្រុមហ៊ុន មេឌីវ៉េត អាហារ៍ណា នីហារ៍ណា<br>: MEDIVET Co., Ltd |
| **អាសយដ្ឋាន** (Address) | : ផ្ទះលេខ323ង ផ្លូវណតប្រ៊ិត ក្រុម៣ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ<br>: #323 Street Norbrigth Group3 Sangkat Tektla Khan Sensok Capital Phnom Penh |
| **ផលិតដោយ** (Manufactured by) | : Veterinary Pharmaceutical Industry, Italy |
| **សុពលភាព** (Validity) | : ៥ឆ្នាំ (គិតចាប់ពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៨ ដល់ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣)<br>: **5 years** (From 11st July 2018 to 10th July 2023) |

បសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម សមាសធាតុ (**ENCEFAL-VAC**)នេះ បានទទួលការអនុញ្ញាតឱ្យចុះបញ្ជីដោយអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ។
The ENCEFAL-VAC is Registered by General Directorate of Animal Health and Production.

ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជា
អគ្គនាយកនៃអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ

# គំរូវិញ្ញាបនបត្រសម្រាប់ការចុះបញ្ជីចំណីសត្វ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ
លេខ: សផស/នផបន

ថ្ងៃ ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី ខែឧសភា ឆ្នាំ២០១៨

## វិញ្ញាបនបត្រចុះបញ្ជីចំណីសត្វ

REGISTRATION CERTIFICATE - COMPOUND FEED

យោងគោលការណ៍អនុញ្ញាតលេខ៤១៣២ កសក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៨ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**លេខបញ្ជិកា** (Registration Number) : FR01 0006/0518 BMF - GDAHP

**ឈ្មោះពាណិជ្ជកម្ម** (Trade Name) : GOLD HORSE 211

**ឈ្មោះទូទៅ** (Common Name) : ចំណីសម្រេចសម្រាប់កូនមាន់សាច់
: Compound Feed for Broiler Chicks

**ប្រភេទនៃទម្រង់ផ្សំ** : គ្រាប់ (Type of Formulation) : Granule

**បរិមាណនៃសារធាតុចិញ្ចឹម** : ប្រូតេអ៊ីន ២១% , ខ្លាញ់ ៤% , ជាតិសរសៃ ៥% , កាល់ស្យូម ០.៧-១.៥%, ផូស្វ័រ ០.៦-១.២%, សំណើម ១៣% , ថាមពល ៣០០០គីឡូកាឡូរី/គ.ក្រ
(Content of Nutrition) : Crude Protein 21% , Crude Fat 4% , Crude Fiber 5% , Calcium 0.7-1.5%, Phosphorus 0.6-1.2%, Moisture 13%, Metabolisable Energy 3000Kcal/kg

**ប្រភេទចំណីសត្វ** (Type of Animal Feed) : សម្រាប់កូនមាន់អាយុពី ១ថ្ងៃ ដល់ ១០ថ្ងៃ
: For a day-old chicks to 10 days

**ផ្តល់ជូនចំពោះ** (Issued to) : ក្រុមហ៊ុន ប៊ីអឹម ហ្វីដ (ខេមបូឌា) ឯ.ក
: BM Feed (Cambodia) Co., Ltd

**អាសយដ្ឋាន** (Address) : ភូមិពោងពាយ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ
: Phum Pourng Peay, Sangkat Phnom Penh Thmey, Khan Sensok, Capital Phnom Penh

**ផលិតដោយ** (Manufactured by) : ក្រុមហ៊ុន BINH MINH ប្រទេសវៀតណាម
: BINH MINH CO., LTD, VIETNAM

**សុពលភាព** (Validity) : ៥ឆ្នាំ (គិតចាប់ពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៨ ដល់ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៣)
: **5 years** (From 26th April 2018 to 25th April 2023)

ចំណីមាន់(**GOLD HORSE 211**)នេះ បានទទួលការអនុញ្ញាតឱ្យចុះបញ្ជីដោយអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ និងត្រូវមានបិទស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរ ស្របតាមឧបសម្ព័ន្ធ៣ នៃប្រកាសលេខ០៥១ ប្រក.កសក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៨។

The animal Compound feed (**GOLD HORSE 211**) is registered by GDAHP, and to be labelled the product information in Khmer language in accordance with annex 3 of Prakas No. 051 dated 16th January 2018.

ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជា
អគ្គនាយកនៃអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ

# សេចក្តីព្រាងប្រកាសដែលកំពុងប្រជុំពិភាក្សានៅថ្នាក់ក្រសួង

| ល.រ | បទដ្ឋានគតិយុត្ត | កសក | គណៈរដ្ឋមន្ត្រី | រដ្ឋសភា | ព្រឹទ្ធសភា |
|---|---|---|---|---|---|
| ១ | ព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈបសុពេទ្យ (មាត្រា៧៣) | √ | | | |
| ២ | អនុក្រឹត្យស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការធ្វើអាជីវកម្មពិឃាតសត្វ និងទីកន្លែងកែច្នៃ បឋមផលិតផលសត្វ (មាត្រា៥២) | √ | | | |
| ៣ | ប្រកាសអន្តរក្រសួងស្តីពីគំរូសំណុំលិខិតដោះស្រាយបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ (មាត្រា១០១) | √ | | | |
| ៤ | ប្រកាសអន្តរក្រសួងស្តីពីកម្រៃសេវាកម្មតាមប្រភេទនីមួយៗ (មាត្រា៩៣) | √ | | | |
| ៥ | ប្រកាសស្តីពីនីតិវិធីក្នុងការត្រួតពិនិត្យនូវបសុឱសថ ចំណីសត្វ និងវត្ថុធាតុដើម ឬសារធាតុ សកម្មឬសារធាតុបន្ថែមដែលនាំចូល នាំចេញ ផលិតលាយផ្សំ វេចខ្ចប់ជាថ្មី (មាត្រា៩២) | √ | | | |
| ៦ | ប្រកាសស្តីពីការកំណត់ប្រភេទ និងលក្ខខណ្ឌតម្រូវនៃបទដ្ឋានបច្ចេកទេសសម្រាប់សត្តឃាតដ្ឋាន ស្ថិតក្រោមអនុក្រឹត្យមាត្រា៥២ | √ | | | |

- គោលបំណងៈការពារសុខភាពសត្វ សុខុមាលភាពសត្វ សុខភាពសាធារណៈ និងបរិស្ថាន
- កំណត់បទដ្ឋានបច្ចេកទេសទៅតាមចំណាត់ថ្នាក់ខ្នាត នីមួយៗ



# ការធ្វើអធិការកិច្ច

- យោងតាមមាត្រា៩៧ នៃច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ បានចែងថា រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវកំណត់គុណវុឌ្ឍិ និងតែងតាំងមន្ត្រីអធិការកិច្ចសុខភាពសត្វនិងផលិតកម្មសត្វ តាមសំណើរបស់អង្គភាពទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ដើម្បីបំពេញភារកិច្ច និងទទួលខុសត្រូវចំពោះគ្រប់សកម្មភាពពាក់ព័ន្ធក្នុងវិស័យសុខភាពសត្វនិងផលិតកម្មសត្វ។
- យោងតាមសេចក្តីសម្រេចលេខ១៣៦ សសរ.កសក ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ២០១៩ រដ្ឋមន្ត្រីបានតែងតាំងមន្ត្រីរបស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីខេត្ត ចំនួន ២៦៧រូប ជាមន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វ។


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ១៣៦ សសរ.កសក

សេចក្តីសម្រេច
ស្តីពី
ការតែងតាំងមន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វ

ប្រការ២.-

មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វ ដូចមានកំណត់ក្នុងប្រការ១ខាងលើ មានសមត្ថកិច្ចធ្វើអធិការកិច្ចនិងត្រួតពិនិត្យលើគ្រប់សកម្មភាពដែលពាក់ព័ន្ធនឹងសត្វ ផលិតផលសត្វ ចំណីសត្វ បសុឱសថ វត្ថុធាតុដើម សារធាតុសកម្ម និងសារធាតុបន្ថែមគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយត្រូវអនុវត្តមុខងារនិងភារកិច្ចរបស់ខ្លួនស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទប្បញ្ញត្តិផ្សេងទៀតជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

ថ្ងៃ ច័ន្ទ ៦ កើត ខែ ផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០១៩
រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

វេង សាខុន

# ១.សិទ្ធិ និងភារកិច្ចរបស់មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វ

- យោងតាមមាត្រ៨៧នៃច្បាប់សុខភាពសត្វ និងផលិតកម្មសត្វចែងថា៖

**នៅពេលអនុវត្តមុខការ មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វ មានភារកិច្ចនិងសិទ្ធិដូចខាងក្រោម៖**

✓ តម្រូវឲ្យរូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើសកម្មភាពពាក់ព័ន្ធនឹងសត្វ ឬផលិតផលសត្វ ផ្តល់ព័ត៌មាន និងបង្ហាញលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬឯកសារពាក់ព័ន្ធក្នុងសកម្មភាពរបស់ខ្លួន។

✓ ដកយកសំណាក វត្ថុវិភាគរបស់សត្វ ផលិតផលសត្វ ចំណីសត្វ សារធាតុបន្ថែម បសុឱសថ ឬវត្ថុ ធាតុដើមនៃផលិតផលទាំងនោះ ដែលជាកម្មវត្ថុនៃការត្រួតពិនិត្យ និងធ្វើការវិភាគភ្នាក់ងារចម្លងជំងឺ ឬធ្វើការវិភាគផ្ទៀងផ្ទាត់បមាណឺយដើម។

✓ ដកហូតជាបណ្ដោះអាសន្ននូវលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬឯកសារដែលពាក់ព័ន្ធក្នុងករណីដែលអ្នកកាន់លិខិតអនុញ្ញាត ឬវិញ្ញាបនបត្រនោះ ប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ។

✓ ចាប់យកវត្ថុតាង និងកសាងសំណុំរឿងនៃបទល្មើសស្របតាមនីតិវិធី។

✓ ចាត់វិធានការផ្សេងទៀតនៅក្នុងក្របខ័ណ្ឌនៃការអនុវត្តច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ។

ក្នុងករណីសង្ស័យមានភាពមិនប្រក្រតី ឬសង្ស័យមានបទល្មើសពាក់ព័ន្ធនឹងសុខភាពសត្វ និងផលិតម្មសត្វ សុខុមាលភាពសត្វ បសុឱសថ និងចំណីសត្វ មន្ត្រីអធិការកិច្ចសុខភាពសត្វនិងផលិតកម្មសត្វមានសមត្ថកិច្ច តាមដាន ស្រាវជ្រាវ ត្រួតពិនិត្យ និងជំរុញការ អនុវត្តច្បាប់នេះនៅក្នុងដែនសមត្ថកិច្ចសាមី ដើម្បីបង្ការ ទប់ស្កាត់ លុបបំបាត់ហានិភ័យនៃជំងឺសត្វ និងបង្ក្រាបបទល្មើស នៅតាម៖

១. កន្លែង ឬស្នាក់ការត្រួតពិនិត្យតាមច្រកទ្វារព្រំដែនដែលកំណត់ដោយរាជរដ្ឋាភិបាល។

២. ស្ថានីយចត្តាឡីស័កសត្វ និងផលិតផលសត្វ ទីកន្លែង ឬកសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វ។

៣. ទីកន្លែងព្យាបាលសត្វ ផ្សារសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ ទីកន្លែងអាជីវកម្មសត្វ សត្តឃាតដ្ឋាន ទីកន្លែងកែច្នៃបឋមផលិតផលសត្វ និងកន្លែងតាំងលក់។

៤. គ្រឹះស្ថានអាជីវកម្មពាណិជ្ជកម្ម និងសេវាកម្ម ទីកន្លែងតាំងលក់ និងទីកន្លែងផ្សេងទៀតដែលរូបធាតុ សេនេទិកសត្វ ចំណីសត្វ បសុឱសថ និងផលិតផលសត្វ ត្រូវបានរក្សាទុក ឬលក់ចែកចាយ។

៥. គ្រឹះស្ថានស្រាវជ្រាវ មន្ទីរពិសោធន៍ ស្ថានីយពិសោធន៍។

៦. ទីកន្លែងផ្សេងទៀតក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានហានិភ័យ ឬសង្ស័យថាមានហានិភ័យ បណ្តាលមកពីការឆ្លងរាលដាលជំងឺសត្វ ឬសង្ស័យថាមានបទល្មើសពាក់ព័ន្ធនៃច្បាប់នេះ។

## ២. ដំណើរការអធិការកិច្ចរបស់មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វ

**យោងតាមមាត្រា៩៨ នៃច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ បានចែងថា៖ ក្នុងពេលប្រតិបត្តិការអនុវត្តច្បាប់ មន្ត្រីអធិការកិច្ចសុខភាពសត្វនិងផលិតកម្មសត្វ ត្រូវមានលិខិតបញ្ជាបេសកកម្ម និងត្រូវស្លៀកពាក់ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ។**

- នៅក្នុងដំណើរការអធិការកិច្ចសុខភាពសត្វនិងផលិតកម្មសត្វ ក្នុងករណីមានភស្តុតាងជាក់ស្តែងបញ្ជាក់អំពីការប្រព្រឹត្តល្មើសនឹងច្បាប់ មន្ត្រីអធិការកិច្ចសុខភាពសត្វនិងផលិតកម្មសត្វ មានសិទ្ធិតម្រូវឲ្យរូបវន្តបុគ្គល ឬនីតិបុគ្គលដែលទទួលខុសត្រូវលើប្រតិបត្តិការដែលពាក់ព័ន្ធនឹងបទល្មើស ផ្អាករាល់សកម្មភាពជាបណ្តោះអាសន្ន ឬទាំងស្រុង (មាត្រា១០២ នៃច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ)។
- ក្នុងករណីបានជួបប្រទះបទល្មើសជាក់ស្តែង មន្ត្រីនៃអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវផ្តល់ព័ត៌មានជាបន្ទាន់ដល់មន្ត្រីអធិការកិច្ចសុខភាពសត្វនិងផលិតកម្មសត្វ មានសមត្ថកិច្ចដែលនៅជិតបំផុតដើម្បីចាត់ការតាមនីតិវិធី (មាត្រា១០០)។
- មន្ត្រីអធិការកិច្ចសុខភាពសត្វនិងផលិតកម្មសត្វ អាចស្នើសុំជំនួយពីអាជ្ញាធរដែនដីគ្រប់ថ្នាក់ អង្គភាពប្រដាប់អាវុធ ឬអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមបង្ក្រាបបទល្មើសដូចមានចែងក្នុងច្បាប់ និងក្នុងប្រតិបត្តិការត្រួត ពិនិត្យបទល្មើស ត្រូវអនុវត្តស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (មាត្រា១០០)។

# រូបភាពចុះធ្វើអធិការកិច្ច















# រូបភាពចុះធ្វើអធិការកិច្ច



# បញ្ហាប្រឈម និងដំណោះស្រាយ

## ❑ .បញ្ហាប្រឈម

១. លិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ នៅមិនទាន់មានគ្រប់គ្រាន់សម្រាប់អនុវត្ត។

២. ការធ្វើអធិការកិច្ចចុះត្រួតពិនិត្យតាមបណ្តាក្រុមហ៊ុន និងដេប៉ូចំណីសត្វ ឬឱសថនៅមានកម្រិត។

៣. ក្រុមហ៊ុន និងដេប៉ូលក់ចំណីសត្វ ឬឱសថ ភាគច្រើននៅបន្តលក់ចំណីសត្វ ឬឱសថ ដែលមានសំបកចាស់ៗ និងលេខបញ្ជិកាចាស់បន្តពីនាយកដ្ឋាននីតិកម្មកសិកម្ម និងមានស្លាកសញ្ញាព័ត៌មានជាភាសាបរទេស ដោយមិនអនុលោមបមាណីយបទដ្ឋានគតិយុត្ត។

៤.ដំណើរការចេញលិខិតអនុញ្ញាតនៅតាមបណ្តារាជធានី ខេត្តមួយចំនួន នៅជួបបញ្ហា។

# ទិសដៅបន្ត

1. បន្តការសម្របសម្រួលក្នុងការកសាងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពណើសុខភាពសត្វ និងផលិតកម្មសត្វ
2. បន្តចុះណែនាំដល់អាជីវករ អ្នកនាំចូល (ក្រុមហ៊ុន) អ្នកលក់ ទិញ បសុឱសថ និងចំណីសត្វ ក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យយល់អំពីបសុឱសថ សារធាតុជីវសាស្រ្ត សម្រាប់ផលិតលាយផ្សំ ដែលត្រូវបានហាមឃាត់
3. ពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ តាមរយៈការធ្វើសន្និធិ នៅតាមក្រុមហ៊ុននាំចេញ នាំចូល កន្លែងវេចខ្ចប់ ដេប៉ូលក់ ចែកចាយ និងកន្លែងដាក់តាំងលក់ ដើម្បីចូលរួមកាត់បន្ថយការប្រើប្រាស់ឱសថប្រឆាំងមេរោគប្រកបដោយទទួលខុសត្រូវ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីកាត់បន្ថយផលប៉ះពាល់សុខភាពសត្វ និងសុខភាពសាធារណៈ ជាពិសេសអ្នកប្រើប្រាស់សាច់ និងផលិតផលមានដើមកំណើយពីសត្វ។



HANDLE ANTIBIOTICS WITH CARE

# សូមអរគុណ